# សេចក្តីប្រកាសព័ត៌មានរួមរបស់កិច្ចប្រជុំពេញអង្គ

ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨

## កិច្ចប្រជុំពេញអង្គលើកទី៤ នៃ អ.វ.ត.ក. បានសម្រេច

កិច្ចប្រជុំពេញអង្គលើកទី៤ ដែលមានរយៈពេលប្រាំថ្ងៃ បានបញ្ចប់នៅថ្ងៃទី៥ ខែកញ្ញាឆ្នាំ២០០៨ នៅទីក្រុងភ្នំពេញ។

វិធានផ្ទៃក្នុងដែលត្រូវបានអនុម័តក្នុងខែមិថុនា ឆ្នាំ២០០៧ តម្រូវឲ្យមន្ត្រីតុលាការកោះប្រជុំពេញអង្គចំនួនពីរលើកក្នុងមួយឆ្នាំ ដើម្បីពិនិត្យនិងធ្វើវិសោធនកម្មចាំបាច់លើវិធានផ្ទៃក្នុងនិងសេចក្តីណែនាំអនុវត្តន៍ ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង និងដើម្បីសម្រេចលើបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃ អ.វ.ត.ក. ដែលបានស្នើឡើងដោយគណៈ-កម្មាធិការរដ្ឋបាលតុលាការ។

ដូចបានកត់សម្គាល់ក្នុងមតិបើកកិច្ចប្រជុំពេញអង្គ ដោយឯកឧត្តមប្រធាន (ចៅក្រម គង់ ស្រ៊ីម) គោលដៅសំខាន់ៗមួយចំនួនត្រូវបានបញ្ចប់រួចហើយជាអាទិ៍ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ នៅថ្ងៃទី៨ ខែសីហា បញ្ជូនរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច ទៅជំនុំជម្រះ។ ដោយសារតែសហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ បច្ចុប្បន្ននេះវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះគឺជាបញ្ហាដែលស្ថិតនៅចំពោះមុខអង្គបុរេជំនុំជម្រះជាអ្នកធ្វើការសម្រេចសេចក្តីនាអនាគតដ៏ខ្លីខាងមុខនេះ។

ក្នុងចំណោមសមិទ្ធិផលតុលាការទាំងនេះ អង្គជំនុំជម្រះសម្រេចបាននូវលទ្ធផល សកម្មភាពរដ្ឋបាល និងគ្រប់គ្រងជាក់ស្តែង និងសំខាន់ៗមួយចំនួនដូចជាការស្នើធ្វើវិសោធនកម្មទៅលើសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ, ការចូលរួមរបស់ជនរងគ្រោះ និងការការពារចំពោះសាក្សី, បានធ្វើឲ្យអង្គភាពជនរងគ្រោះបំពេញកិច្ចការរបស់ខ្លួនបានពេញលេញ (បច្ចុប្បន្នអង្គភាពបានទទួលពាក្យបណ្តឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៨០០ សហចៅក្រមស៊ើបអង្កេតបានទទួលយកចំនួន២៨ ដាក់បញ្ចូលក្នុងសំណុំរឿងលេខ១) ការមកដល់របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងដែលជាការចាប់ផ្តើមនៃការងាររបស់ខ្លួន ព្រមទាំងរៀបចំសាលសវនាការឲ្យដំណើរការទៅបាន។

កិច្ចប្រជុំពេញអង្គលើកទី៤នេះ បានពិនិត្យរាល់សកម្មភាពទាំងអស់របស់តុលាការដូចបាន រៀបរាប់ខាងលើ និងបានអនុម័តវិសោធនកម្មក្នុងវិធានផ្ទៃក្នុង ដែលភាគច្រើននៃវិសោធនកម្មនោះគឺជាការកែសម្រួលនីតិវិធីដោយផ្អែកលើបទពិសោធន៍ជាក់ស្តែងក្នុងដំណើរការក្នុងរយៈពេលប្រាំមួយខែចុងក្រោយរបស់ខ្លួន។

កិច្ចប្រជុំពេញអង្គបានសម្រេចលើបញ្ហាសំខាន់ៗមួយចំនួនដូចខាងក្រោមនេះ៖

- តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធី ត្រូវបានទទួលការពិចារណាដោយយកចិត្តទុកដាក់។ វិសោធនកម្មលើវិធានផ្ទៃក្នុង រួមបញ្ចូលទាំងការតម្រូវឲ្យជនរងគ្រោះ ដែលមានបំណងចង់ធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីដាក់ពាក្យសុំនៅអង្គភាពជនរងគ្រោះ យ៉ាងហោចណាស់១០ថ្ងៃ មុនសវនាការបឋម។ កិច្ចប្រជុំបានឯកភាពលើវិធានការមួយចំនួនទៀត ដូចជាអំណាចរបស់សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះក្នុងការតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីបង្កើតក្រុម និងជ្រើសរើសមេធាវីមួយរូបដើម្បីតំណាងក្រុមរបស់ខ្លួន និងបានឯកភាពថាបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបញ្ចប់នៅពេលជនត្រូវចោទ ឬជនជាប់ចោទទទួលមរណភាព។

- ចៅក្រម និងសហព្រះរាជអាជ្ញាបានបង្ហាញឲ្យឃើញនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការអនុវត្តនៅគ្រប់កិច្ចដំណើរការនីតិវិធីទាំងអស់ក្នុង អ.វ.ត.ក. ប្រកបដោយឯករាជ្យភាព ភាពស្មោះត្រង់ និងសេចក្តីសុចរិតទៀងត្រង់។ នេះជាការបញ្ជាក់អំពីការប្តេជ្ញារបស់យើងដែលបានរួមគ្នាជាឯកច្ឆ័ន្ទធ្វើវិសោធនកម្ម លើក្រមសីលធម៌ចៅក្រម។ អត្ថបទទាំងស្រុងនឹងមានផ្សាយលើវ៉ិបសាយរបស់ អ.វ.ត.ក.។

- ដោយទទួលស្គាល់ក្នុងបរិបទនៃអង្គជំនុំជម្រះវិសាមញ្ញនេះថាកំណត់ហេតុបម្រើឲ្យគោលបំណងពីរក្នុងការជួយដល់ដំណើរការជំនុំជម្រះសេចក្តីនិងបណ្តឹងឧទ្ធរណ៍ ក៏ដូចជាការបន្សល់ទុកនូវកេរ្តិ៍មរតក របស់អង្គជំនុំជម្រះ កិច្ចប្រជុំពេញអង្គបានពិភាក្សាអំពីការប្រើប្រាស់កំណត់ហេតុជាលាយលក្ខណ៍ អក្សរ, ជារូបភាព និងសម្លេង និងបានឯកភាពគ្នាឲ្យប្រើប្រាស់វិធីសាស្ត្រមួយដើម្បីកត់ត្រាទុកនូវកំណត់ហេតុពេញលេញ របស់កិច្ចដំណើរការនីតិវិធីទាំងឡាយ។

- យើងបានសម្រេចលើបញ្ហាបច្ចេកទេសដែលពាក់ព័ន្ធនឹងវិសាលភាពនៃបណ្តឹងឧទ្ធរណ៍ផងដែរ។ ដូច្នេះកិច្ចប្រជុំពេញអង្គបានសម្រេចអនុម័ត យកយុទ្ធសាស្ត្រដែលបានអនុវត្តកន្លងមកនៅសាលាក្តីព្រហ្មទណ្ឌអន្តរជាតិផ្សេងៗចំពោះករណីដែលមាន លក្ខណៈស្មុគស្មាញ និងធ្ងន់ធ្ងរស្រដៀងគ្នានឹងការកម្រិតឲ្យប្តឹងសាទុក្ខបានតែទៅលើករណីដែលមានកំហុសឆ្គងនៃបញ្ហាអង្គច្បាប់ដែលនាំឲ្យមានមោឃភាពក្នុងសេចក្តីសម្រេច ឬករណីដែលមានកំហុសឆ្គងនៃអង្គហេតុដែលធ្វើឲ្យសេចក្តីសម្រេចរបស់តុលាការមិនមានភាពយុត្តិធម៌។

- ក្នុងបរិបទនៃវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តកិច្ចប្រជុំពេញអង្គបានពិចារណាលើតុល្យភាពគ្នារវាងអាណត្តិរបស់ អ.វ.ត.ក. ក្នុងការរៀបចំឲ្យមានសវនាការសាធារណៈ និងការរក្សាឲ្យបាននូវតម្រូវការនៃការលាក់ការសម្ងាត់។ កិច្ចប្រជុំពេញអង្គបានអនុម័តគោលការណ៍ថ្មីសម្រាប់ចាត់ចំណាត់ថ្នាក់ ព័ត៌មានដែលមានក្នុងសំណុំរឿង។

- ចៅក្រម និងសហព្រះរាជអាជ្ញាអន្តរជាតិបានសម្តែងនូវសេចក្តីដឹងគុណដល់លោក David Tolbert ដែលជាទីប្រឹក្សាពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិចំពោះភារកិច្ចដែលលោកបានបំពេញកន្លងមក ដើម្បីធ្វើឲ្យអង្គជំនុំជម្រះស្ថិតក្នុងស្ថានភាពមួយមានលំនឹងជាងមុន និងបានជួយឲ្យអង្គជំនុំជម្រះប្រតិបត្តិការប្រកបដោយភាពរលូនជាងមុន។

- ចៅក្រមថ្មីចំនួនពីររូបគឺលោកស្រី Catherine Marchi-Uhel (បារាំង) ជាចៅក្រមបម្រុងអន្តរជាតិសម្រាប់អង្គជំនុំជម្រះសាលាកំពូល និងលោក Siegfried Blunk (អាឡឺម៉ង់) ជាចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានធ្វើសច្ចាប្រណិធានចូលកាន់តំណែងនៅចំពោះមុខកិច្ចប្រជុំពេញអង្គ។

- វាល់វិសោធនកម្មលើវិធានផ្ទៃក្នុងនឹងមានផ្សព្វផ្សាយ ១០ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំពេញអង្គនេះបញ្ចប់។

ជារួមយើងអាចធ្វើសេចក្តីរាយការណ៍បានថា កិច្ចប្រជុំពេញអង្គលើកទី៤នេះ បានបន្តធ្វើកិច្ចការដែលជាទម្លាប់របស់ខ្លួនដូចកាលក្នុងកិច្ចប្រជុំពេញអង្គមុនៗដែរ ដោយបានពិភាក្សាគ្នាលើបញ្ហាស្មុគស្មាញជាច្រើនដែលបានរៀបចំយ៉ាងល្អពីគណ:កម្មាធិការទាំងពីរ និងលេខាធិការដ្ឋាន។ កិច្ចពិភាក្សាទាំងនេះបានប្រព្រឹត្តទៅប្រកបដោយស្មារតីស្រុះស្រួលគ្នា និងស្មារតីពិភាក្សាជាក្រុម។